

ព័ត៌មានកម្មវិធី SPCR

# ការប្រែប្រួលអាកាសធាតុ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
កម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
ខែមិថុនា ឆ្នាំ២០១៦ លេខ ៥

## កិច្ចប្រជុំលើកទី៤ របស់ក្រុមការងារសម្របសម្រួលកម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ

នៅព្រឹកថ្ងៃទី៣០ខែមិថុនាឆ្នាំ២០១៦ នៅសណ្ឋាគារកាំបូឌីយ៉ាណា កិច្ចប្រជុំលើកទី៤ របស់ក្រុមការងារសម្របសម្រួលកម្មវិធី SPCR បានប្រព្រឹត្តទៅក្រោមការដឹកនាំសហប្រធានដោយឯកឧត្តម ប៉ុន សារឿន អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាអនុប្រធានក្រុមការងារសម្របសម្រួលកម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) និងឯកឧត្តម វ៉ាន់ មុនីនាថ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងបណ្ឌិត Ancha Srinivasan អ្នកឯកទេសផ្នែកការប្រែប្រួលអាកាសធាតុនៃធនាគារអភិវឌ្ឍន៍អាស៊ី។ គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីពិភាក្សាពីវឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគចំនួន៧ក្រោមកម្មវិធី SPCR ជាមួយក្រសួងពាក់ព័ន្ធសំខាន់ៗដែលអនុវត្តគម្រោងទាំងនេះរួមមានក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងកិច្ចការនារី ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងផែនការ ក្រសួងមហាផ្ទៃ (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) និងក្រសួងបរិស្ថាន។ ចំនុចសំខាន់ៗដែលត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំរួមមាន៖



- អនុសាសន៍នានាពាក់ព័ន្ធនឹងឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុតាមវិស័យសម្រាប់ប្រទេសកម្ពុជា ដើម្បីអាចយកមកប្រើប្រាស់បានឱ្យមានប្រសិទ្ធភាព
- ការធ្វើសេចក្តីសម្រេចចិត្តលើដំណើរការ និងជំហាននៃការសិក្សាលម្អិតពីលទ្ធភាពគម្រោងបន្សាំដើម្បីរៀបចំសំណើគម្រោងវិនិយោគដែលធន់នឹងអាកាសធាតុដើម្បីស្វែងរកមូលនិធិអន្តរជាតិ
- ធ្វើបច្ចុប្បន្នភាពស្តីពីការជ្រើសរើសអង្គការសង្គមស៊ីវិលដើម្បីអនុវត្តសកម្មភាពនិងវឌ្ឍនភាពការបន្សាំក្នុងវិស័យកសិកម្មធនធានទឹក ការដឹកជញ្ជូន និងការអភិវឌ្ឍទីក្រុង។



នៅរសៀលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ក្រុមការងារក៏បានប្រជុំពិគ្រោះយោបល់អ្នកពាក់ព័ន្ធថ្នាក់ជាតិស្តីពីសូចនាករកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុដើម្បីដាក់ពិន្ទុលើវឌ្ឍនភាពនៃការអនុវត្តទៅតាមសូចនាករ




សំខាន់ៗដែលកំណត់ដោយមូលនិធិវិនិយោគអាកាសធាតុ។ ជាលទ្ធផលនៃកិច្ចប្រជុំ អ្នកឯកទេសអន្តរជាតិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅប្រទេសហ្វីលីពីន នឹងរៀបចំជារបាយការណ៍តាមដានត្រួតពិនិត្យប្រចាំឆ្នាំ២០១៥ដើម្បីផ្ញើជូនមូលនិធិវិនិយោគអាកាសធាតុ និងដៃគូអភិវឌ្ឍន៍នានា។ សូចនាករសំខាន់ៗសម្រាប់ការវាស់វែងរួមមាន (១) កម្រិតនៃការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (២)ការពង្រឹងសមត្ថភាពរាជរដ្ឋាភិបាលក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ(៣)ការពង្រឹងយន្តការសម្របសម្រួលដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុ (៤ )កម្រិតនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលត្រូវបានបង្កើតឡើង និងធ្វើតេស្តសាកល្បង។ ក្រសួងស្ថាប័នពាក់ព័ន្ធដែលបានដាក់ពិន្ទុលើសូចនាករទាំងនោះគឺបានផ្អែកលើការប្រៀបធៀបជាមួយលទ្ធផលដែលសម្រេចបានក្នុងការដាក់ពិន្ទុនៅក្នុងឆ្នាំ២០១៤កន្លងមក។ សូចនាករភាគច្រើនត្រូវបានដាក់ពិន្ទុល្អជាងពេលមុនពីចន្លោះពិន្ទុលេខ០ដល់លេខ១០បើទោះបីសូចនាករខ្លះត្រូវបានដាក់ពិន្ទុនៅដដែលក៏ដោយ។នេះបង្ហាញឱ្យឃើញថាកម្ពុជាកំពុងឆ្ពោះទៅការអនុវត្តឆ្លើយតបនឹងការបន្សាំ និងភាពធន់នឹងអាកាសធាតុទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិកាន់តែប្រសើរជាងមុន។

## ឯកសារថ្មី៖ ការពិនិត្យមើលឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុដែលមានស្រាប់តាមវិស័យនៃប្រទេសកម្ពុជា




ក្រុមការងារមជ្ឈមណ្ឌលអន្តរជាតិ សម្រាប់ការគ្រប់គ្រងបរិស្ថាន នៅក្រោមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នាពេលថ្មីៗនេះ បានចងក្រងឯកសារ "ការពិនិត្យមើលឧបករណ៍ជ្រើសរើស ហានិភ័យអាកាសធាតុដែលមានស្រាប់តាមវិស័យនៅកម្ពុជា" ។ ឯកសារនេះពិពណ៌នាពីឧបករណ៍ដែលមានស្រាប់ និងវាយតម្លៃពីភាពសមស្របត្រឹមត្រូវហើយនេះ ក៏ស្នើឱ្យមានឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុថ្មី សម្រាប់បរិបទប្រទេសកម្ពុជា។

ឯកសារបានកំណត់នូវឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុ ដែលសមស្របត្រឹមត្រូវសម្រាប់គម្រោងផ្សេងៗដែលរៀបចំដោយក្រសួងសំខាន់ៗសម្រាប់កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ដូចជាក្រសួងធនធានទឹក និងឧតុនិយម (ធនធានទឹក) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (កសិកម្ម) ក្រសួងសាធារណការ និងដឹកជញ្ជូន (ផ្លូវជាតិ និងផ្លូវខេត្ត និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង) និងក្រសួងអភិវឌ្ឍន៍ជនបទ (ផ្លូវជនបទ និងហេដ្ឋារចនាសម្ព័ន្ធ)។ ឯកសារនេះនឹងបំពេញបន្ថែមលើឧបករណ៍ជ្រើសរើសបរិស្ថាន និងសង្គមទូទៅដែលប្រើប្រាស់ដោយក្រសួងបរិស្ថាន។

## ការចាប់ផ្តើមយន្តការគាំទ្រសង្គមស៊ីវិលដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅសហគមន៍

គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ដែល អង្គការភ្លែនអន្តរជាតិកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) កំពុងអនុវត្តផ្នែកយន្តការគាំទ្រសង្គមស៊ីវិលក្រោមកញ្ចប់ទី២ ដោយបានជ្រើសរើសជាផ្លូវការស្របតាមនីតិវិធីរបស់ADB។ ជាលទ្ធផល អង្គការសង្គមស៊ីវិលចំនួន១៩ត្រូវបានជ្រើសរើសដើម្បីផ្តល់ហិរញ្ញប្បទានខ្នាតតូចសម្រាប់អនុវត្ត សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍ ។ លទ្ធផលនៃការជ្រើសរើសនេះត្រូវបានបង្ហាញនៅក្នុងសិក្ខាសាលាថ្នាក់ជាតិមួយ កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ដោយមានការអញ្ជើញចូលរួមពីមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារអនុវត្តកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ។

តាមរយៈជំនួយបច្ចេកទេសអង្គការភ្លែនអន្តរជាតិបានឱ្យដឹងថា៖ បន្ទាប់ពីបានទទួលកម្មវិធីបណ្តុះបណ្តាលពីអង្គការភ្លែនអន្តរជាតិដូចជា ការសិក្សាប៉ាន់ប្រមាណកាត់បន្ថយភាពងាយរងគ្រោះ(VRA) ការកសាង និងរៀបចំសំណើគម្រោង បទពិសោធន៍នានាពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុរួចមក អង្គការ សង្គមស៊ីវិលចំនួន១៩ត្រូវបានជ្រើសរើសចេញពីការចម្រាញ់ក្នុងចំណោម

អង្គការដែលបានដាក់សំណើចំនួន៣៣ ។ គម្រោងការបញ្ជ្រាបភាពធន់នឹង អាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នឹងត្រូវបានផ្តល់ហិរញ្ញប្បទានសរុបចំនួន ១ ៤០០ ០០០ដុល្លារសហរដ្ឋអាមេរិក ជូនដល់អង្គការទាំង១៩នោះ  ដើម្បីអនុវត្តសកម្មភាពគម្រោងបន្សាំនឹង ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ។ គម្រោងទាំងនោះមានគោលដៅជារួមគឺ បង្កើនសុវត្ថិភាព និងភាពធន់របស់សហគមន៍ ជាពិសេសធ្វើយ៉ាងណាឱ្យស្ត្រី បុរស កុមារ កុមារី ដែលអាចចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងហានិភ័យទាំងឡាយដែលកើតពីការប្រែប្រួលអាកាសធាតុ។ គម្រោងទាំងអស់ដែលបានស្នើឡើងគឺជាចំបងផ្តល់នូវផលប្រយោជន៍




ដល់អ្នកដែលងាយរងគ្រោះចំនួន១១៧,៦០៧ ឬស្មើនឹង ២១,០៣៥គ្រួសារ ដែលស្ថិត នៅក្នុងខេត្តទាំង១៧ ។ គម្រោងទាំងនោះផ្តោតលើតំបន់ភូមិសាស្ត្រផ្សេងៗគ្នាដូចជា តំបន់ទីក្រុង តំបន់ទឹកជំនន់ តំបន់ឆ្នេរ និងតំបន់ខ្ពង់រាបជាដើម ហើយក៏នឹងឆ្លើយតបតម្រូវការផ្សេងៗគ្នានៃក្រុមដែលងាយរងគ្រោះដូចជា កសិករក្រីក្រ ជនក្រីក្រនៅទីក្រុង ស្ត្រី កុមារ ជនជាតិដើមភាគតិច ។ល។ គម្រោងទាំងនោះក៏បានគ្របដណ្តប់លើវិស័យចម្បងៗដូចជា កសិកម្ម ការផ្គត់ផ្គង់ទឹក ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងធនធានធម្មជាតិ ការអប់រំ សុខភាព និងអនាម័យជាដើម ។

ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីមូលនិធិវិនិយោគអាកាសធាតុ និង ធនាគារអភិវឌ្ឍន៍អាស៊ី និង សហការជាមួយគម្រោងវិនិយោគក្រោមកម្មវិធីSPCR ដែលសម្របសម្រួលដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អង្គការផ្លែនអន្តរជាតិនឹងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការកសាងសមត្ថភាពដល់អង្គការសង្គមស៊ីវិលទាំងនោះដើម្បី អនុវត្តសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅតាមសហគមន៍ ។

## ក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុចុះប្រមូលទិន្នន័យលើវិធានការបន្សាំនៅមូលដ្ឋាន ក្នុងខេត្តកោះកុង និងមណ្ឌលគិរី

ចាប់តាំងពីថ្ងៃទី២៥ ខែមេសា ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៦ ក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុបានចុះទស្សនកិច្ចសិក្សាទៅកាន់ខេត្តចំនួនពីរ គឺខេត្តកោះកុង និងមណ្ឌលគិរី ដើម្បីប្រមូលព័ត៌មានពីវិធានការបន្សាំរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ ក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើងក្រោមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (MCRDP) អនុវត្តដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីជួយកំណត់ និងបញ្ជ្រាបការអនុវត្តនៃការបន្សាំទៅក្នុងកម្មវិធីអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍទីក្រុងនិងផ្លូវថ្នល់។ សមាជិកក្រុមការងារដែលបានចុះប្រមូលទិន្នន័យសរុបមានចំនួន៣០នាក់បានអញ្ជើញមកពីក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកិច្ចការនារី និងធនាគារអភិវឌ្ឍន៍អាស៊ី។

ទស្សនកិច្ចចុះសិក្សាខាងលើនេះ ត្រូវបានដឹកនាំដោយឯកឧត្តម សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ឯកឧត្តម ប៉ុន សារឿន អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាអនុប្រធានសម្របសម្រួលកម្មវិធី SPCR លោក ស៊ុំ ធី ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន លោក សួស ពិនរក្ស អ្នកសម្របសម្រួលកម្មវិធី SPCR នៃធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា និងលោកអ៊ូ ច័ន្ទធារិទ្ធ ប្រធានដឹកនាំគម្រោងMCRDP។ ក្រុមការងារត្រូវបានបែងចែកជាក្រុមតាមវិស័យ និងរួមដំណើរដោយអភិបាលរងខេត្តកោះកុង និងមណ្ឌលគិរី អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ និងមន្ត្រីបច្ចេកទេស មកពីមន្ទីរពាក់ព័ន្ធក្នុងខេត្តនីមួយៗ។

ក្រុមការងារបានចុះទៅសិក្សានៅក្នុងឃុំមួយចំនួននិងបានកំណត់វិធានការបន្សាំដែលមានសក្តានុពលចំនួន៥០ករណីសិក្សាដែលនឹងត្រូវវិភាគសម្រាប់ ការអភិវឌ្ឍភាពធន់នឹងអាកាសធាតុតាមវិស័យ។ ឧទាហរណ៍ ការរកឃើញចំនួន២ករណីរបស់ក្រុមការងារពីអាងស្តុកទឹកទុកនៅខេត្តកោះកុង និងព្រែកសិកម្មក្នុងខេត្តមណ្ឌលគិរី ត្រូវបានបង្ហាញដូចខាងក្រោម៖

**<u>អាងស្តុកទឹកទុកនៅខេត្តកោះកុង</u>**



ខេត្តកោះកុងមានអាងស្តុកទឹកមួយចំនួន ដែលត្រូវបានសាងសង់ក្នុងសម័យរបបប៉ុលពត និងនៅតែដំណើរការប្រើប្រាស់បានរហូតមកដល់សព្វថ្ងៃនេះ។ បេសកកម្មនេះ បានចុះទៅសិក្សាជាក់ស្តែងនៅអាងស្តុកទឹកចំនួន៣ (១) អាងស្តុកទឹកបឹងព្រលាន (ទំហំប្រហែល១៧ហិកតា) មានទីតាំងនៅក្រុងខេមរភូមិន្ទ (២) អាងស្តុកទឹកជីត្រេះ និងប្រឡាយស្រោចស្រព (ទំហំ៤៥ហិកតា) ក្នុងឃុំអណ្តូងទឹក ស្រុកបទុមសាគរ និង (៣)អាងស្តុកទឹកបានទៀត(ទំហំ៥០ហិកតា) មានទីតាំងនៅឃុំដងពែង ស្រុកស្រែអំបិលតាមផ្លូវជាតិលេខ៤៨។ ទោះបីយ៉ាងណា នៅឆ្នាំ២០១៦ ជាឆ្នាំដែលមានគ្រោះរាំងស្ងួតអូសបន្លាយយូរប៉ុន្តែអាងស្តុកទឹកទាំងនោះមិនរីងទេ។ សហគមន៍អាចមានទឹកប្រើប្រាស់ដោយពឹងផ្អែកលើអាងស្តុកទឹកទាំងនោះដើម្បីប្រើប្រាស់ប្រចាំថ្ងៃ និងការងារកសិកម្ម ពិសេសនៅឃុំអណ្តូងទឹក និងជីខលើដែលមានស្រះតូចៗ។ អណ្តូងលូ និងអណ្តូងស្នប់មិនមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ទេ។ ក្នុងឱកាសនៃការចុះសិក្សានេះ ក្រុមការងារក៏បានពិភាក្សាជាមួយអាជ្ញាធរស្រុកពីសារៈសំខាន់នៃការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងការថែទាំអាងស្តុកទឹកទាំងនេះ ដោយចាត់ទុកជាវិធានការបន្សាំអាទិភាព និងជាប្រភពទឹកសម្រាប់សហគមន៍ដើម្បីដោះស្រាយភាពប្រឈមនឹងគ្រោះរាំងស្ងួត។

**<u>ព្រៃកសិកម្មក្នុងខេត្តមណ្ឌលគីរី</u>**

ខេត្តមណ្ឌលគីរី មានទីតាំងនៅភាគឥសានប្រទេសកម្ពុជា ដែលជាតំបន់ភ្នំ និងជាខេត្តមួយងាយរងគ្រោះពីគ្រោះមហន្តរាយដែលទំនងនឹងកាន់តែរងផលប៉ះពាល់ខ្លាំងពីការប្រែប្រួលអាកាសធាតុ។ គ្រោះមហន្តរាយសំខាន់ៗក្នុងតំបន់នេះរួមមាន៖ ខ្យល់ក្តៅ គ្រោះរាំងស្ងួត ការហូរច្រោះដី និងទីជម្រាលដែលនាំឱ្យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យកសិកម្មកាន់តែខូចខាតធ្ងន់ធ្ងរ។ កសិករកំពុងស្វែងរកដំណោះស្រាយលើបញ្ហាខាងលើនេះ និងជាលទ្ធផលវិធានការបន្សាំមួយចំនួនត្រូវបានដាក់បញ្ចូលក្នុងសកម្មភាពជីវភាពរស់នៅ ការបង្កើនបច្ចេកទេសព្រៃកសិកម្មទៅក្នុងការដាំដុះដំណាំ។



ឧទាហរណ៍ កសិករមួយចំនួនកំពុងជ្រើសរើសការដាំដំណាំកាហ្វេ និងធូរេន -- ការដាំដំណាំប្រភេទនេះត្រូវការប្រើប្រាស់ទឹកតិចតួច ប៉ុន្តែផ្តល់នូវប្រាក់ចំណេញខ្ពស់សម្រាប់គ្រួសារដែលមានផ្ទៃដីកសិកម្មទំហំប្រមាណ១៥ហិកតា។ កសិករម្នាក់ឈ្មោះ ង៉ែត ចាន់រស្មី ក្នុងចំណោមកសិករដទៃទៀតដែលដាំដំណាំប្រភេទនេះ។ ចំការកាហ្វេត្រូវបានគ្រប់គ្រងយ៉ាងល្អនៅក្នុងម្លប់ និងមានអាយុកាល២០ឆ្នាំ។ បច្ចុប្បន្ន កាហ្វេត្រូវបានប្រមូលផលដោយប្រើប្រាស់កំលាំងពលកម្មតិច និងគ្មានប្រើថ្នាំគីមីសម្លាប់សត្វល្អិតឡើយ។ ទិន្នផលទទួលបានពីបច្ចេកទេសនេះផ្តល់ផលដល់កសិករ ប៉ុន្តែកសិករនៅប្រឈមការលំបាកមួយចំនួនដោយសារតម្រូវការប្រភពទឹកស្រោចស្រពមិនគ្រប់គ្រាន់សម្រាប់ដំណាំធុរេន។ បន្ថែមលើនេះ តម្លៃកាហ្វេមានការធ្លាក់ចុះជាងការរំពឹងទុក។ ដើម្បីធ្វើឱ្យប្រសើរឡើងបច្ចេកទេសនេះ កសិករនឹងត្រូវការបច្ចេកវិទ្យាថ្មីដូចជាការស្រោចស្រពដំណក់ទឹកសម្រាប់ដំណាំធុរេន ការគាំទ្របច្ចេកទេសធ្វើឱ្យប្រសើរឡើងនូវគុណភាពដំណាំកាហ្វេ និងធុរេន ព្រមទាំងការគាំទ្រទីផ្សារ។

## ការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីផលិតកម្មពូជស្រូវធន់នឹងអាកាសធាតុ

កម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មស្រូវធន់ នឹងអាកាសធាតុកំពុងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តយុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹកដែលរួមបញ្ចូលគោលបំណងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងភាពរីកចម្រើនសេដ្ឋកិច្ចដោយបង្កើនផលិតកម្មកសិកម្ម និងទំនើបកម្មចម្រុះ និងធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក។ កម្មវិធីនេះ ក៏នឹងជួយបង្កើនឱកាសសម្រាប់ផលិតកម្មចម្រុះ និងប្រពលវប្បកម្ម ក្នុងប្រព័ន្ធកសិដ្ឋានផ្សេងៗ។



កម្មវិធីអភិវឌ្ឍន៍ វិស័យពាណិជ្ជកម្មស្រូវធន់នឹងអាកាសធាតុ (www.ricesdp.org) ត្រូវបានប្រតិបត្តិការដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ខេត្តគោលដៅគម្រោងគឺ ខេត្តបាត់ដំបង កំពង់ធំ និងព្រៃវែង ដែលមានមន្ទីរតាមខេត្តជម្រុញការអនុវត្ត។ គម្រោងគាំទ្រដោយកម្មវិធីសន្តិសុខស្បៀង និង កសិកម្មសកលដែលមានការចូលរួមពីដៃគូអភិវឌ្ឍន៍ជាច្រើន និងត្រូវបានអនុវត្តដោយមានការគាំទ្រការគ្រប់គ្រង និងបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី។ ចាប់តាំងពីថ្ងៃទី៦ដល់ទី១៥ ខែមិថុនា ឆ្នាំ២០១៦ កម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មស្រូវធន់នឹងអាកាសធាតុ បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីផលិតកម្មពូជស្រូវធន់នឹងអាកាសធាតុ។ អ្នកចូលរួមចំនួន៣០នាក់ រួមមានស្ត្រីចំនួន៩នាក់អញ្ជើញមកពីការិយាល័យកសិកម្មខេត្ត និងស្រុក និងមន្ទីរផ្សេងៗក្នុងខេត្តបាត់ដំបង កំពង់ធំ និងព្រៃវែង បានចូលរួមវគ្គបណ្តុះបណ្តាលនេះ។ សិក្ខាកាមបានរៀនសូត្រពីបច្ចេកទេសធ្វើឱ្យប្រសើរឡើងនូវគុណភាព និងបង្កើនគុណភាពពូជស្រូវក្នុងខេត្តគោលដៅរបស់កម្មវិធី។ ពួកគេក៏ធ្វើឱ្យប្រសើរឡើងពីការផ្ទេរបច្ចេកវិទ្យា និងជំនាញសម្របសម្រួលក្រុមកសិករ ដើម្បីជួយបណ្តុះបណ្តាលក្នុងខេត្តរបស់ខ្លួន។ ជាពិសេសវគ្គបណ្តុះបណ្តាលនេះបានផ្តោតសំខាន់លើការគ្រប់គ្រងទឹកក្នុងស្រែ ការប្រើប្រាស់ដី ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងកត្តាសត្វល្អិតចង្រៃ សាលាកសិករ



ជំនាញ សម្របសម្រួលរបស់អ្នកបណ្តុះបណ្តាល និងវិធានការផលិតកម្មពូជស្រូវផ្សេងៗដើម្បីផលិតស្រូវ។ ការបញ្ចប់វគ្គបណ្តុះបណ្តាលនេះបង្ហាញឱ្យឃើញថា វាជាជំហានក្នុងផែនការជម្រុញការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដេ ីម្បីបង្កើនផលិតកម្មស្រូវធន់នឹងអាកាសធាតុ និងការធ្វើពាណិជ្ជកម្ម។

## រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍សហការគ្នាបង្កើនភាពធន់នឹងអាកាសធាតុជាមួយគ្រោះរាំងស្ងួត



នៅចុងឆ្នាំ២០១៥ កម្ពុជាប្រឈមគ្រោះរាំងស្ងួតដែលមានរយៈពេលអូសបន្លាយ។ គ្រោះរាំងស្ងួតបានប៉ះពាល់ដល់ប្រជាជនរាប់សែនគ្រួសារនៅទូទាំងប្រទេស។ កសិករមិនអាចសូម្បីតែប្រមូលផលដំណាំតិចតួចនៅលើផ្ទៃដីដែលរាំងស្ងួតរបស់ពួកគាត់ទេ។ ស្ត្រីនៅតាមជនបទត្រូវចំណាយពេលវេលាយ៉ាងយូរ ដើម្បីធ្វើដំណើរស្វែងរកទឹកសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងចិញ្ចឹមសត្វ។

ក្រោមការដឹកនាំឈ្លាសវៃ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសឱ្យអន្តរាគមន៍បន្ទាន់ជួយដល់កសិករដែលរងគ្រោះដោយសារគ្រោះរាំងស្ងួតនៅទូទាំងប្រទេស។ បន្ថែមពីនេះ អាជ្ញាធរនៅថ្នាក់ជាតិ និងក្រោមជាតិបានខិតខំប្រឹងប្រែងអស់លទ្ធភាពចែកចាយទឹកដល់សហគមន៍ដែលទទួលរងគ្រោះពិសេសស្ត្រី និងកុមារ។ ការស្តារអាងទឹក ការជួសជុលអណ្តូងទឹក ការជីកស្រះនៅទូទាំងប្រទេស ត្រូវបានអនុវត្តជាជំហានៗដើម្បីជៀសវាងការខ្វះទឹកប្រើប្រាស់នៅពេលជួបគ្រោះរាំងស្ងួត។

ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងដោះស្រាយឆ្លើយតបនឹងស្ថានភាពបន្ទាន់នេះ ដោយធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីចាត់វិធានការបង្កើនភាពធន់នឹងអាកាសធាតុទៅនឹងគ្រោះរាំងស្ងួត និងហានិភ័យអាកាសធាតុ។ កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ដែលគាំទ្រដោយមូលនិធិវិនិយោគអាកាសធាតុតាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី កំពុងគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុ ដល់រាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធី SPCR មានគម្រោងវិនិយោគចំនួន៨ដែលបាននឹងពង្រឹងទាំងអន្តរាគមន៍ទន់ និងអន្តរាគមន៍រឹងនូវភាពធន់នឹងអាកាសធាតុក្នុងវិស័យសំខាន់ៗពាក់ព័ន្ធនឹងសេដ្ឋកិច្ចកម្ពុជាដែលងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ រួមមានកសិកម្ម ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍ

ទីក្រុង និងការដឹកជញ្ជូន។



នៅក្នុងវិស័យធនធានទឹក គម្រោងបង្កើនការគ្រប់គ្រងហានិភ័យគ្រោះទឹកជំនន់ និងរាំងស្ងួតក្នុងខេត្តពោធិ៍សាត់ កំពុងត្រូវបានអនុវត្តដោយក្រសួងធនធានទឹក និងឧតុនិយម។គម្រោងនេះជាផ្នែកមួយនៃគម្រោងកាត់បន្ថយ និងគ្រប់គ្រងហានិភ័យគ្រោះទឹកជំនន់ និងរាំងស្ងួតក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលគម្រោងនេះកំពុងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងការត្រៀមបង្ការដើម្បីគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដូចដែលប្រទេសកម្ពុជាយើងកំពុងប្រឈម។ វិធានការនានារួមមានបង្កើនប្រព័ន្ធទិន្នន័យព័ត៌មានទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងតំបន់ ការរៀបចំលក្ខខណ្ឌសម្រាប់ជួយដល់ការគ្រប់គ្រងគ្រោះទឹកជំនន់និងរាំងស្ងួត និងការធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកបានប្រសើរឡើង។ វិធានការទាំងនេះ នឹងជួយពង្រឹងដល់មជ្ឈមណ្ឌលជាតិព្យាករណ៍ទឹកជំនន់ និងបង្កើនសមត្ថភាពសហគមន៍លើការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។



គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទធន់នឹងអាកាសធាតុ ដែលមានក្រសួងអភិវឌ្ឍន៍ជនបទ ដោយសហការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ កំពុងអនុវត្តការផ្តួចផ្តើមហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទធន់នឹងអាកាសធាតុក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ គម្រោងនេះ គឺបង្កើនជីវភាពរស់នៅប្រជាជនដែលធន់នឹងអាកាសធាតុ ពិសេសក្រុមដែលងាយរងគ្រោះដោយដាក់បញ្ចូលការគ្រប់គ្រងគ្រោះទឹកជំនន់ និងរាំងស្ងួតទៅក្នុងការអភិវឌ្ឍផ្លូវជនបទ និងការស្តារអាងស្តុកទឹកខ្នាតតូច។ គម្រោងនេះ នឹងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងទឹកជំនន់ និងការបង្ហូរទឹកនៅសងខាងផ្លូវសម្រាប់សហគមន៍កំឡុងពេលរដូវទឹកជំនន់ទន្លេមេគង្គ។ ជាលទ្ធផល ស្ត្រី និងបុរសដែលរស់នៅក្នុងសហគមន៍លិចទឹក នឹងអាចធ្វើដំណើរឆ្លងកាត់ផ្លូវបានគ្រប់រដូវកាលទៅកាន់ទីផ្សារ និងសេវាផ្សេងៗដែលពួកគាត់ត្រូវការ។

ក្រសួងសាធារណការ និងដឹកជញ្ជូន ក៏បានពាក់ព័ន្ធក្នុងកិច្ចខិតខំប្រឹងប្រែងនេះផងដែរ។ ស្ថិតនៅក្រោមគម្រោងនានាដូចជាផ្លូវធន់នឹងអាកាសធាតុ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធន់នឹងទឹកជំនន់ គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូងនៃគម្រោងមហាអនុតំបន់ទន្លេមេគង្គដែលលើក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង ក្រុងបាវិត និងអ្នកលឿង និងកំពុងធ្វើការកសាងហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុដើម្បីធ្វើឱ្យប្រសើរឡើង នូវហេដ្ឋារចនាសម្ព័ន្ធទីក្រុង និង បង្កើនភាពធន់នឹងអាកាសធាតុតាមរយៈការគ្រប់គ្រងសំណល់រាវ និងរឹង ការការពារច្រាំងទន្លេ ការធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងទឹកជំនន់ និងប្រព័ន្ធបង្ហូរទឹក ព្រមទាំងការរៀបចំបទដ្ឋានជើងទេរផ្លូវ និងការដឹកប្រឡាយបង្ហូរទឹកដើម្បីកាត់បន្ថយការហូរច្រោះដោយវិធីសាស្ត្រវិស្វកម្មបៃតង។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏កំពុងចាត់វិធានការសម្រាប់ការបន្សាំតាមរយៈការបង្កើនភាពធន់ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងការបន្សាំផ្តោតលើមុខជំនួញ ជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មស្រូវធន់នឹងអាកាសធាតុ។ គម្រោងនេះ គឺការបង្កើនផលិតកម្មគុណភាពស្រូវនៅកម្ពុជាស្របនឹងការអភិរក្សធនធានធម្មជាតិ។ លទ្ធផលសំខាន់ៗមួយចំនួនរួមមាន៖ តំបន់ប្រើប្រាស់ដីកសិកម្មត្រូវបានធ្វើឱ្យប្រសើរឡើង ហេដ្ឋារចនាសម្ព័ន្ធសង្វាក់ផលិតកម្មស្រូវធន់នឹងអាកាសធាតុកាន់តែប្រសើរឡើង បង្កើនសេវាគាំទ្រសង្វាក់ផលិតកម្មស្រូវដើម្បីបង្កើនគុណភាពស្រូវកម្ពុជា ច្បាប់ និងបទបញ្ញត្តិបរិស្ថាន ត្រូវបានបង្កើតដើម្បីសម្របសម្រួលពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ។ គម្រោងក៏នឹងសាកល្បងការធានាដល់ការដាំដំណាំទៅតាមអាកាសធាតុ។

ស្ថិតក្រោមការអន្តរាគមន៍ទាំងនេះ ក្រសួងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូពាក់ព័ន្ធតាមខេត្តព្រមទាំងសហគមន៍ និងសង្គមស៊ីវិល ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ធន់នឹងអាកាសធាតុសម្រាប់រយៈពេលយូរអង្វែង។ កសិករកម្ពុជានឹងត្រូវប្រឈមគ្រោះរាំងស្ងួតទៀតនាពេលអនាគត។ ប៉ុន្តែវិធានការទាំងនេះត្រូវបានត្រៀមបង្ការដើម្បីបង្កើនសមត្ថភាពរាជរដ្ឋាភិបាល និងសហគមន៍អាចគ្រប់គ្រងហានិភ័យ និងកាត់បន្ថយផលប៉ះពាល់លើជីវភាពរស់នៅ និងសកម្មភាពប្រចាំថ្ងៃរបស់ប្រជាជន។

# ការកសាងសមត្ថភាពដើម្បីការរៀបចំផែនការអភិវឌ្ឍន៍ធន់នឹងអាកាសធាតុ-- សមិទ្ធផលសំខាន់ៗដែលទទួលបាន



គម្រោងហិរញ្ញប្បទានឥតសំណងជំនួយ សហប្រតិបត្តិការបច្ចេកទេស សម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (MCRDP) កំពុងគាំទ្ររាជរដ្ឋាភិបាលដើម្បីបង្កើនភាពធន់របស់ប្រទេស ទៅនឹងការប្រែប្រួលអាកាសធាតុ។ តាមរយៈគម្រោងMCRDP នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រោមអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព កំពុងអនុវត្តជាជំហានៗ ដាក់បញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំកម្មវិធី និងការរៀបចំគោលនយោបាយរបស់វិស័យសំខាន់ៗ ដើម្បីចូលរួមការអភិវឌ្ឍប្រទេសកម្ពុជាលើវិស័យកសិកម្ម ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍទីក្រុង និងការដឹកជញ្ជូន។

ក្នុងខែកក្កដា ឆ្នាំ២០១៥ គម្រោងMCRDP បានរៀបចំសិក្ខាសាលាស្តីពីវិសាលភាពការងាររបស់គម្រោងរយៈពេល៥ឆ្នាំក្នុងកិច្ចសហការជាមួយមន្ត្រីសំខាន់ៗដែលអញ្ជើញមកពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកិច្ចការនារី ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនិងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។បន្ទាប់ពីសិក្ខាសាលានេះ ក្រសួងដែលអញ្ជើញចូលរួមត្រូវបានចងក្រងបង្កើតជាក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីអនុវត្តផែនការការងាររយៈពេល៥ឆ្នាំ។ រយៈពេលមួយឆ្នាំក្រោយមក ក្រុមការងារការបន្សាំទទួលបានសមិទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

## ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុតាមវិស័យដែលមានលក្ខណៈសមស្របសម្រាប់កម្ពុជា



សមាជិក ក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានបង្កើនជំនាញ ក្នុងការប្រើប្រាស់ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុ និងមានសមត្ថភាពដាក់បញ្ចូលវិធានការណ៍បន្សាំទៅក្នុងកម្មវិធីតាមវិស័យ និងគោលនយោបាយ។ ដំណើរការនៃការអនុវត្តជាជំហានរួមមាន៖ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ សមាជិកក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ចំនួន២១នាក់ និងអ្នកពាក់ព័ន្ធសំខាន់ៗ ចំនួន៥២នាក់ក្នុងបានចូលរួមក្នុងការបណ្តុះបណ្តាលស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងការរៀបចំផែនការបន្សាំនៅខេត្តបាត់ដំបង។ វគ្គបណ្តុះបណ្តាលនេះបានផ្តល់នូវចំណេះដឹងទ្រឹស្តី និងការចុះអនុវត្ត ជាក់ស្តែងដើម្បីប្រើប្រាស់វិធានការណ៍បន្សាំ ការរៀបចំបទដ្ឋានសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ អន្តរាគមន៍ ការអភិវឌ្ឍកសិកម្មនិងការគ្រប់គ្រងធនធានទឹក។ ដើម្បីអនុវត្តចំណេះដឹងនេះ មន្ត្រីរដ្ឋាភិបាល ចំនួន៣៥នាក់ត្រូវបានបង្ហាញជូនពីឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុផ្សេងៗនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលកាលពីខែមេសា ឆ្នាំ២០១៦។ បន្ថែមពីនេះ ដើម្បីសិក្សាពីឧបករណ៍ទាំងនេះ អ្នកចូលរួមបានផ្តល់នូវធាតុចូលមួយចំនួនដើម្បីជ្រើសរើសឧបករណ៍មួយណាដែលសមស្របសម្រាប់ការប្រើប្រាស់ ក្នុងការបង្កើត ក្របខណ្ឌគ្រប់គ្រងហានិភ័យអាកាសធាតុសម្រាប់ការរៀបចំបទអន្តរាគមន៍នាពេលអនាគតក្នុងវិស័យរបស់ខ្លួន។

## វិធានការការបន្សាំត្រូវបានចងក្រងសម្រាប់ការចែករំលែកចំណេះដឹង៖

កាលពីប៉ុន្មានខែកន្លងនេះ សមាជិកក្រុមការងារការបន្សាំបានប្រែក្លាយចំណេះដឹងដែលបានសិក្សាពីវគ្គបណ្តុះបណ្តាលខាងលើមកកំណត់ និងចងក្រងការអនុវត្តការបន្សាំដែលអាទិភាពនៅក្នុងខេត្តងាយរងគ្រោះបំផុតនៅកម្ពុជា ដូចជាខេត្តបាត់ដំបង កោះកុង កំពង់ធំ ត្បូងឃ្មុំ មណ្ឌលគិរី ពោធិ៍សាត់ ព្រៃវែង និងកំពង់ឆ្នាំង។ ផ្អែកលើលទ្ធផលដែលបានរកឃើញពីការវាយតម្លៃនៅមូលដ្ឋានទាំងនេះ ក្រុមការងារបច្ចេកទេសគម្រោងMCRDP និងក្រុមការងារការបន្សាំ បានធ្វើសេចក្តីព្រាងករណីសិក្សាលើការអនុវត្តការបន្សាំសម្រាប់កសិកម្ម ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍទីក្រុង និងការដឹកជញ្ជូន។

ករណីសិក្សាទាំងនេះនឹងត្រូវបានចងក្រងដោយបានឧទាហរណ៍នានា ដែលដកស្រង់ចេញពីការអនុវត្តរបស់ប្រទេសផ្សេងៗ ដើម្បីរៀបចំជាឯកសារណែនាំការបន្សាំសម្រាប់វិស័យនីមួយៗ។ ឯកសារនឹងចងក្រងសម្រាប់ជាតម្រូវការរបស់អ្នករៀបចំគោលនយោបាយ និងផែនការកម្មវិធី អ្នកបច្ចេកទេស និងអ្នកពាក់ព័ន្ធផ្សេងៗនៅកម្ពុជា សម្រាប់ជាមគ្គុទេសក៏ក្នុងការកំណត់វិធានការជាក់លាក់ដើម្បីពិចារណានូវការដាក់បញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងគោលនយោបាយ និងកម្មវិធីនានា។

## ការរៀបចំការសិក្សាលម្អិតពីលទ្ធភាពគម្រោងការបន្សាំនឹងការប្រែប្រួលអាកាសធាតុកំពុងដំណើរការៈ



តាមរយៈការប្រើប្រាស់ឧបករណ៍ ដែលបានសិក្សា ដែលត្រូវបានគាំទ្រដោយក្រុមការងារគម្រោងMCRDP នៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ កំពុងសហការជាមួយក្រសួងសំខាន់ៗក្នុងដំណើរជាជំហានៗ ដើម្បីវាយតម្លៃការសិក្សាលម្អិតពីលទ្ធភាពកសាងសំណើគម្រោង។ វិស័យនីមួយៗនឹងជ្រើសរើសអាទិភាពចំនួន១ ឬ២គម្រោងបន្សាំដែលជ្រើសរើសពីគម្រោងការបន្សាំរបស់ក្រសួងនីមួយៗ។ ក្រុមការងារTA នឹងសហការជាមួយក្រុមការងារការបន្សាំ ដើម្បីរៀបចំការសិក្សាលម្អិតក្នុងដំណើរការរៀនផង និងអនុវត្តផងពីរបៀបប្រើប្រាស់ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុនៅពេលរៀបចំគម្រោង។ បន្ថែមពីនេះ ក្រុមការងារTA កំពុងសហការ និងជួយក្រសួងនីមួយៗដើម្បីកំណត់យន្តការគាំទ្រហិរញ្ញវត្ថុ ដូច្នេះក្រសួងអាចបង្កើតចេញពីសំណើគម្រោងទៅជាសកម្មភាពជាក់លាក់សម្រាប់ភាពធន់នឹងអាកាសធាតុ។

វិធីសាស្ត្ររបស់គម្រោងMCRDP គឺការកសាងសមត្ថភាពផ្តោតលើការរៀនទ្រឹស្តីផង និងការអនុវត្តផង ដូច្នេះក្នុងរយៈពេល១ឆ្នាំៗ ក្រសួងសំខាន់ៗកាន់តែមានជំនាញក្នុងការរៀបចំផែនការអភិវឌ្ឍន៍ធន់នឹងអាកាសធាតុ។ ប្រការនេះ ក្រសួងសំខាន់ៗដែលចូលរួមជាមួយគម្រោងMCRDP នឹងត្រៀមរួចជាស្រេចនូវសំណើគម្រោងលើការដោះស្រាយតម្រូវការការបន្សាំរយៈពេលមធ្យម និងយូរអង្វែងក្នុងវិស័យខ្លួនដែលឱ្យស្របនឹងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលបានកំណត់ក្នុងឆ្នាំ២០០៦។

គម្រោងMCRDP ស្ថិតក្រោមកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ គាំទ្រថវិកាដោយមូលនិធិវិនិយោគអាកាសធាតុនៃកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុតាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍អន្តរជាតិដទៃទៀត។

ADB

CLIMATE INVESTMENT FUNDS

**ព័ត៌មានបន្ថែម៖**

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី

លោក មាស សុផល នាយកដឹកនាំគម្រោង

លោក អ៊ូ ច័ន្ទជារិទ្ធ ប្រធានគ្រប់គ្រងគម្រោង

អគ្គលេខា ធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

នាយកដ្ឋានប្រែប្រួលអាកាសធាតុ

អគារមរតកតេជោ ឡូត៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ៖ ៨៥៥ ២៣ ៥៣១៤ ៧៧៧

អ៊ីម៉ែល៖ adbspcrta8179@gmail.com

គេហទំព័រ៖ http://www.spcrcambodia.org/kh/